

กองบัญชาการป้องกัน
ภูมิภาคทหารที่ ๓
๑๖ สิงหาคม
កិច្ចប្រជុំ វិសាមញ្ញ
វិសាមញ្ញ
ជាមួយនិង
ថ្ងៃទី ១៦ ខែសីហា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កងទ័ពជើងគោក
យោធភូមិភាគទី៣

ថ្ងៃសៅរ៍ ៨រោច ខែស្រាពណ៍ ឆ្នាំរោង សប្តស័ក ព.ស ២៥៦៩
កំពង់ស្ពឺ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំវិសាមញ្ញ គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ កម្ពុជា - ថៃ (RBC) ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥ នៅខេត្តត្រាត ព្រះរាជាណាចក្រថៃ

កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ កម្ពុជា-ថៃ (RBC) បានប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៥ នៅខេត្តត្រាត ព្រះរាជាណាចក្រថៃ និងភាគីថៃធ្វើជាម្ចាស់ផ្ទះ។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ទោ អ៊ុយ ហៀង** មេបញ្ជាការយោធភូមិភាគទី៣ និងជាសហប្រធាននៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។ គណៈប្រតិភូថៃដឹកនាំដោយ **ឯកឧត្តម ឧត្តមនាវីឯក អភិនាត សាប់ប្រះសើត** មេបញ្ជាការការពារព្រំដែនច័ន្ទបុរី-ត្រាត និងជាសហប្រធាននៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។

ភាគីទាំងពីរបានប្តេជ្ញាចិត្តក្នុងការអនុវត្តទៅតាមលទ្ធផលនៃកិច្ចប្រជុំពិសេសរវាង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ភូមិថាំ វិឆាយ៉ាឆៃ** នាយករដ្ឋមន្ត្រីស្តីទីនៃព្រះរាជាណាចក្រថៃ ដែលបានប្រព្រឹត្តទៅនៅទីក្រុងពូត្រាចាយ៉ា កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ដោយប្រទេសម៉ាឡេស៊ីធ្វើជាម្ចាស់ផ្ទះ និងសហការរៀបចំដោយសហរដ្ឋអាមេរិក ព្រមទាំងមានការចូលរួមយ៉ាងសកម្មពីសាធារណរដ្ឋប្រជាមានិតចិន។ ភាគីទាំងពីរក៏បានបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការអនុវត្តតាមលទ្ធផលនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលបានធ្វើឡើងនៅទីក្រុងគូឡាឡាំពួរ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។

បន្ថែមពីនេះ ភាគីទាំងពីរបានឯកភាពគ្នាក្នុងការរក្សាទំនាក់ទំនងជាប្រចាំរវាងតំបន់យោធា និងបណ្ដាយោធភូមិភាគ ព្រមទាំងអង្គភាពនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ និងខិតខំដោះស្រាយរាល់បញ្ហាដោយសន្តិវិធី ដើម្បីជៀសវាងនូវការប៉ះទង្គិចគ្នា។ ភាគីទាំងពីរបានគូសបញ្ជាក់ពីការតាំងចិត្តវិជ្ជមាន និងស្មារតីឆ្ពោះទៅមុខក្នុងការពង្រឹងទំនាក់ទំនងតាមរយៈការប្រាស្រ័យទាក់ទងគ្នានេះ។ ភាគីទាំងពីរក៏បានលើកឡើងផងដែរអំពីសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងបន្ថែមទៀតនៅគ្រប់កម្រិត ដើម្បីកសាងទំនុកចិត្ត និងលើកកម្ពស់ភាពជាអ្នកជិតខាងល្អ។

ភាគីទាំងពីរបានឯកភាពគ្នាជាគោលការណ៍ក្នុងការបង្កើតក្រុមការងារសម្របសម្រួល (CG) ដើម្បីពង្រឹងទំនាក់ទំនងនៅគ្រប់កម្រិត រួមបញ្ចូលទាំងថ្នាក់មេបញ្ជាការ ក្រុមការងារទំនាក់ទំនងតាមព្រំដែន កងកម្លាំងឈរជើងតាមតំបន់ព្រំដែន និងអង្គភាពប្រតិបត្តិការតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ក្នុងគោលបំណងដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងបញ្ចៀសការប៉ះទង្គិចគ្នា។ ខ្លឹមសារលម្អិតនឹងត្រូវយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC)។

នៅក្នុងកិច្ចប្រជុំ កម្ពុជាបានបញ្ជាក់ឡើងវិញនូវសារៈសំខាន់នៃការជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងការដោះមីនមនុស្សធម៌ ដោយលើកឡើងថា កិច្ចការនេះអាចវិវត្តទៅមុខបាន គឺអាស្រ័យទៅលើការអនុវត្តយ៉ាងពេញលេញនូវបទឈប់បាញ់ និងការវិលត្រលប់មករកប្រក្រតីភាពឡើងវិញតាមបណ្ដោយព្រំដែន។ ដោយសារការកំណត់ខណ្ឌសីមាព្រំដែនកំពុងដំណើរការ ដូចនេះ ការដោះមីននេះ អាចចាប់ផ្ដើមពិចារណាអនុវត្តបាននៅក្នុងតំបន់ដែលមានកំណត់ខណ្ឌសីមាច្បាស់លាស់ ឬតំបន់ដែលគ្មានជម្លោះលើខ្សែបន្ទាត់ព្រំដែនដែលមានការឯកភាពគ្នាដោយគណៈកម្មការព្រំដែនចម្រុះនៃប្រទេសទាំងពីរ (JBC)។ ដោយសារគណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC) មិនមានអាណត្តិក្នុងការធ្វើការសម្រេចចិត្តលើកិច្ចការងារដោះមីន ដូច្នេះ បញ្ហានេះគួរតែត្រូវបានយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលគ្រោងធ្វើឡើងនៅពេលឆាប់ៗខាងមុខនេះ ដូចដែលបានព្រមព្រៀងគ្នាដោយភាគីទាំងពីររួចហើយ។

ពាក់ព័ន្ធនឹងបញ្ហាការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) កម្ពុជាបញ្ជាក់ជំហរក្នុងការយកចិត្តទុកដាក់ខ្ពស់លើបញ្ហានេះ ក៏ដូចជាបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត។ កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនេះ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយអាស៊ាន និងដៃគូអន្តរជាតិដទៃទៀត ហើយសម្រេចបានលទ្ធផលជាក់ស្ដែងផងដែរ។ កន្លងមក កម្ពុជាបានសហការជាមួយថៃ ក្នុងការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ហើយបញ្ហានេះអាចនឹងត្រូវយកទៅពិភាក្សា

បន្ថែមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) នាពេលខាងមុខ ដោយសារប្រទេសទាំងពីរទទួលរងផលប៉ះពាល់ដូចគ្នា។

កម្ពុជាក៏បានគូសបញ្ជាក់ផងដែរអំពីភាពចាំបាច់ក្នុងការជៀសវាងសកម្មភាពទាំងឡាយណាដែលអាចបង្កឱ្យមានភាពតានតឹងកើតឡើងជាយថាហេតុ ដោយរាប់បញ្ចូលទាំងការពោយបន្លាលួស និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ជាពិសេសលំនៅឋានរបស់ប្រជាពលរដ្ឋ ព្រមទាំងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ឬព័ត៌មានមិនពិត ដោយហេតុថាសកម្មភាពទាំងនេះអាចបំផ្លាញទំនុកចិត្ត និងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងបង្កើតបរិយាកាសក្នុងការរក្សាស្ថិរភាព និងសន្តិភាព។

ក្នុងកិច្ចខិតខំប្រឹងប្រែងស្តារប្រក្រតីភាពឡើងវិញតាមបណ្តោយព្រំដែន កម្ពុជាបានជំរុញឱ្យភាគីទាំងពីរស្វែងរកវិធានការសំខាន់ៗ និងជាក់ស្តែងដែលអាចអនុវត្តបាន ដើម្បីឱ្យទំនាក់ទំនងលើគ្រប់វិស័យវិលត្រឡប់ទៅរកស្ថានភាពធម្មតាវិញឱ្យបានឆាប់រហ័ស។ សកម្មភាពទាំងនេះនឹងជួយលើកកម្ពស់ភាពជឿជាក់ និងទំនុកចិត្តរវាងគ្នាទៅវិញទៅមក ហើយក៏អាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើអាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរផងដែរ។

កិច្ចប្រជុំវិសាមញ្ញនេះ បានបញ្ចប់ដោយការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ភាគីទាំងពីរ ក្នុងការកសាងលើការ វិវត្តជាវិជ្ជមាន ដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី និងជំរុញទំនាក់ទំនងរវាងប្រជាជន និងប្រជាជនឱ្យកាន់តែជិតស្និទ្ធ។ ភាគីទាំងពីរក៏បានឯកភាពគ្នាក្នុងការរៀបចំកិច្ចប្រជុំបន្ទាប់របស់គណៈកម្មាធិការកិច្ចការព្រំដែនថ្នាក់យោធភូមិភាគ (RBC) ក្នុងរយៈពេលមួយខែ ក្រោយកិច្ចប្រជុំវិសាមញ្ញនេះ ដោយប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

* * * * * * * * *

*Unofficial Translation*

**Press Release**

**The Outcomes of the Cambodia-Thailand Extraordinary Regional Border Committee (RBC) Meeting on 16 August 2025, Trat Province, Kingdom of Thailand**

The Cambodia–Thailand Extraordinary Regional Border Committee (RBC) Meeting was held on 16 August 2025 in the Kingdom of Thailand, hosted by the Thai side. The Cambodian delegation was led by His Excellency Major General **Uy Hieng**, Commander of the 3rd Military Region and Co-Chairman of the Extraordinary RBC Meeting. The Thai delegation was led by His Excellency Vice Admiral **Aphichat Sapprasert**, Commander of the Chanthaburi and Trat Border Defense Command and Co-Chairman of the Extraordinary RBC Meeting.

Both sides committed to implementing the outcomes of the Special Meeting between Samdech **Moha Borvor Thipadei Hun Manet**, Prime Minister of the Kingdom of Cambodia, and **His Excellency Phumtham Wechayachai**, Acting Prime Minister of the Kingdom of Thailand, held in Putrajaya on 28 July 2025, hosted by Malaysia and co-organized by the United States, with the active participation of the People's Republic of China. They also reaffirmed their commitment to implementing the outcomes of the Extraordinary General Border Committee (GBC) Meeting held in Kuala Lumpur on 7 August 2025.

In addition, both sides agreed to maintain regular communication between all army areas, military regions, and units along the Cambodian-Thai border, and to strive to resolve all issues peacefully while avoiding clashes. They underscored the positive momentum and forward-looking spirit in strengthening relations through these engagements. Both sides also underlined the importance of further intensifying communication at all levels to build trust and promote good neighbourliness.

Both sides agreed in principle to establish a coordinating group (CG) to enhance communication at all levels, including between commanders, border liaison working groups, standing forces in the border areas, and operational units along the Cambodia-Thailand border, with the aim of resolving all issues peacefully and avoid clashes. The details will be discussed in the next RBC Meeting.

During the Meeting, Cambodia reaffirmed the importance of advancing humanitarian demining, noting that progress depends on the full implementation of the ceasefire and a return to normalcy along the border. As border demarcation is currently underway, demining can be considered in areas that are demarcated or in non-disputed areas, as agreed upon by the Joint Boundary Commissions (JBC) of the two countries. Since the RBC does not have the mandate to make decisions on demining, this issue should be addressed at the upcoming GBC Meeting, which is scheduled to take place soon, as already agreed by both sides.

With regard to online scams, Cambodia stressed that it takes this matter seriously, alongside with other forms of transnational crime. Cambodia has made significant efforts to combat these issues, working closely with ASEAN and other international partners, and has achieved tangible results. Cambodia and Thailand have already cooperated in tackling online scams, and this issue can be further discussed at the upcoming GBC Meeting, as both countries are equally affected.

Cambodia also underscored the importance of avoiding actions that could inadvertently increase tensions, including the laying of barbed wire, destruction existing infrastructure—particularly civilian residential structures—and the dissemination of fake news or false information, as such developments risk eroding trust and undermining efforts to maintain a stable and peaceful environment.

In an effort to restore normalcy along the border, Cambodia strongly urged both sides to explore all necessary and practical measures to normalize relations in all areas as soon as possible. This would help promote mutual trust and confidence, while also minimizing any adverse impacts on the lives and livelihoods of the people in both countries.

This Extraordinary Meeting concluded with a strong commitment by both sides to build on this positive momentum to further strengthen bilateral relations and foster closer people-to-people ties. Both sides also agreed to convene another RBC Meeting within one month after this Extraordinary Meeting, with Cambodia as the host.

*********